# គណៈកម្មាធិការទីប្រឹក្សាប្រចាំសហគមន៍ (CAC) សំរាប់
# ប្រជាសហគមន៍ និងក្រុមមាតាបិតា / អ្នកអាណាព្យាបាល នៃកម្មវិធីអប់រំពិសេសនៃសង្កាត់សាលារៀនអូកឡិនដ៍

## <u>កិច្ចប្រជុំប្រចាំខែ សំរាប់ឆ្នាំសិក្សា 2010-2011</u>

យើងខ្ញុំគោរពអញ្ជើញលោកអ្នកមកចូលរួមក្នុងកិច្ចប្រជុំនានារបស់គណៈកម្មាធិការទីប្រឹក្សាប្រចាំសហគមន៍ (CAC) សំរាប់ប្រជាសហគមន៍ និងក្រុមមាតាបិតា / អ្នកអាណាព្យាបាល នៃកម្មវិធីអប់រំពិសេសនៃសង្កាត់សាលារៀនអូកឡិនដ៍ ប្រចាំខែរបស់យើង ដែលធម្មតាធ្វើនៅថ្ងៃច័ន្ទ ក្នុងសប្តាហ៍ទីមួយជារៀងរាល់ខែ ចាប់ពីម៉ោង 7 ល្ងាចដល់ម៉ោង 9 យប់។ នេះគឺជាឱកាសល្អសំរាប់លោកអ្នកទទួលដំណឹងអំពីសេវាកម្មអប់រំពិសេស, សួរពត៌មានពីអ្នកគ្រប់គ្រង, ចូលប្រឡូកក្នុងសង្គម និងបង្កើតបណ្តាញមួយជាមួយនឹងក្រុមមាតាបិតា និងអ្នកអាណាព្យាបាល, អ្នកមានវិជ្ជាជីវៈ និងប្រជាសហគមន៍។ លើកលែងតែកិច្ចប្រជុំលើកទីដំបូងប្រចាំឆ្នាំរបស់យើងនេះចេញ ដែលប្រធានបទដូចតទៅនេះ គឺជាប្រធានបទសាកល្បង ហើយអាចមានការផ្លាស់ប្តូរ អាស្រ័យលើមតិយោបល់ពីប្រជាសហគមន៍ :

| | |
|---|---|
| **13 កញ្ញា** | លោកអគ្គនាយក Tony Smith, ការណែនាំឲ្យស្គាល់អ្នកគ្រប់គ្រង និងយល់ដឹងអំពីទស្សនៈវិស័យថ្មីនៃកម្មវិធីអប់រំពិសេស សំរាប់ឆ្នាំសិក្សា 2010-2011 |
| **4 តុលា** | នីតិវិធីនៃកម្មវិធី IEP: ពត៌មានសំខាន់ និងវិធីសាស្រ្តសំរាប់ជោគជ័យក្នុងកម្មវិធី IEP |
| **1 វិច្ឆិកា** | កិច្ចសហការរវាងបុគ្គលិកប្រកបដោយវិជ្ជាជីវៈសុខភាព និងអប់រំ |
| **6 ធ្នូ** | វេទិកាចំហ (ពុំមានវត្តមាននៃនាយកនៃកម្មវិធីអប់រំពិសេសទេ) គិតគូរអំពីការជ្រើសរើសប្រធានបទសំរាប់អនាគត់, បោះឆ្នោតជ្រើសរើសសំរាប់គណៈកម្មាធិការ CAC |
| **3 មករា** | ដំណើរឆ្ពោះទៅរកភាពមិនពឹងពាក់លើអ្នកដទៃទៀតក្នុងនាមជាមនុស្សពេញវ័យ; គំរោងការផ្លាស់ប្តូរ និងជីវិតក្រោយពីបញ្ចប់កម្មវិធី IEP |
| **7 កុម្ភៈ** | កម្មវិធីអប់រំពិសេសនៃសាលាព្រីស្គូល : ស្ថាបនាគ្រឹះរឹងមាំ |
| **7 មីនា** | កម្មវិធីសហគមន៍នាពេលរដូវក្តៅ |
| **4 មេសា** | ការគ្រប់គ្រងភាពតានតឹងសំរាប់ក្រុមគ្រួសារកុមារអប់រំពិសេស |
| **2 ឧសភា** | វេទិកា (ពុំមានវត្តមាននៃនាយកនៃកម្មវិធីអប់រំពិសេសទេ) |
| **6 មិថុនា** | របាយការណ៍ចុងឆ្នាំរបស់នាយកនៃកម្មវិធីអប់រំពិសេស |

កិច្ចប្រជុំទាំងអស់ ជាធម្មតា សុទ្ធតែមានឱកាសឲ្យចូលជួបជំរាបសួរសំណេះសំណាលគ្នា ឡើងប្រកាស់ដំណឹង ដឹងឮអំពីបញ្ហាបារម្ភនៃប្រជាសហគមន៍ និងជួបពិភាក្សាគ្នា ជាមួយនឹងនាយកនៃកម្មវិធីអប់រំពិសេស។

កិច្ចប្រជុំនានាគឺធ្វើនៅក្នុងសាលា **MetWest High School, 314 E. 10th St.** រវាងផ្លូវលេខ **2nd Ave** និង **4th Ave**។

បើសិនជាលោកអ្នកត្រូវការអ្នកជួយបកប្រែភាសា ឬត្រូវការអ្នកជួយមើលកូន នៅពេលជួបប្រជុំនេះ សូមប្រាប់យើងខ្ញុំឲ្យបានដឹងមួយសប្តាហ៍មុនពេលបើកកិច្ចប្រជុំ តាមរយៈអ៊ីមែលទៅកាន់ CACOakland@gmail.com ឬក៏ទូរស័ព្ទទៅ កាន់លេខ 879-2708។ សំរាប់តារាងពេលប្រជុំទាន់សម័យនេះ សូមចុចមើលក្នុងវិបសៃរបស់យើង http://www.ousd.k12.ca.us/PECCAC។

## <u>តើគណៈកម្មាធិការ CAC នេះត្រូវធ្វើអ្វីខ្លះ?</u>

**ក្រមអប់រំ 30 EC 56194 សិទ្ធិអំណាចនៃគណៈកម្មាធិការទីប្រឹក្សាប្រចាំសហគមន៍; ទំនួលខុសត្រូវលេខ 56194**។ គណៈកម្មាធិការទីប្រឹក្សាប្រចាំសហគមន៍ ត្រូវមានសិទ្ធិអំណាច និងបំពេញទំនួលខុសត្រូវនានា ដូចបានកំណត់ច្បាស់លាស់នៅក្នុងផែនការមូលដ្ឋានរបស់ខ្លួន។ ទំនួលខុសត្រូវនានា រួមមាន ប៉ុន្តែមិនកំណត់ថាមានតែដូចតទៅនេះទេ (ក) ផ្តល់ឱវាទអំពីច្បាប់ប្រតិបត្តិនៃអង្គភាពរដ្ឋបាលក្នុងវិស័យផែនការមូលដ្ឋានអប់រំពិសេសទាក់ទិនទៅនឹងការរៀបចំបង្កើតការកែប្រែ និងការពិនិត្យមើលផែនការមូលដ្ឋាន។ អង្គភាពត្រូវពិនិត្យមើល និងត្រូវពិចារណាលើមតិយោបល់ចេញពីគណៈកម្មាធិការទីប្រឹក្សាប្រចាំសហគមន៍; (ខ) ផ្តល់ជាអនុសាសន៍នូវអាទិភាពប្រចាំឆ្នាំ ដើម្បីដោះស្រាយផែនការ; (គ) ជួយក្នុងកម្មវិធីសិក្សា សំរាប់មាតាបិតា និងជួយប្រមែប្រមូលមាតាបិតា និងបុគ្គលិកស្ម័គ្រចិត្ត ដែលអាចជួយកិច្ចការអនុវត្តន៍ផែនការ; (ឃ) ជួយជំរុញឲ្យប្រជាសហគមន៍ចូលរួមសហការក្នុងការបង្កើត និងការពិនិត្យលើផែនការមូលដ្ឋាន; (ច) ជួយគាំទ្រសកម្មភាពនានាក្នុងនាមជាមនុស្សដែលត្រូវការកម្មវិធីអប់រំពិសេស; (ឆ) ជួយឲ្យមាតាបិតាបានយល់ដឹងអំពីសារៈសំខាន់នៃការមករៀនទៀងទាត់រាល់ថ្ងៃនៃសិស្សសាលា។